**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# រោងចក្រ ខ្វាន់ឌុម អ៊ីតែរីល (ខេមបូឌា) លីមីធីត
# និង
# តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
# រោងចក្រ ខ្វាន់ឌុម អ៊ីតែរីល (ខេមបូឌា) លីមីធីត

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០នាទី នៅក្នុងរោងចក្រ **ខ្វាន់ឌុម អ៊ីតែរីល (ខេមបូឌា) លីមីធីត** មានទីតាំងអគារF១១ ផ្លូវវេងស្រេង ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត និងសហជីពមូលដ្ឋានប្រចាំរោងចក្រ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា៖ ដោយសារតែក្រុមហ៊ុនយើងមានការបញ្ជាទិញធ្លាក់ចុះជាង៥០% និង ខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិតដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូច្នេះក្រុមហ៊ុនសម្រេចព្យួកិច្ចសន្យាការងាររបស់កម្មករនិយោជិតសរុបចំនួន**១០៣៤នាក់** (ស្រី៩៥៤នាក់) ក្នុងចំណោមកម្មករនិយោជិត ១១៨៦នាក់ (ស្រី ១០៥៧នាក់) រយៈពេលចំនួន**០៩ថ្ងៃ** គឺចាប់ពី**ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០២៣** នៅក្នុងអំឡុងពេលនៃការព្យួរការងារក្រុមហ៊ុនផ្តល់ជូនកម្មករនិយោជិតដូចខាងក្រោម៖

១. ក្រុមហ៊ុនសំរេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១០៣៤នាក់ ចាប់គិតពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២៣ នឹងចូលធ្វើការវិញនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២៣។
២. ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថមចំនួន១៧ដុល្លា(ដប់ប្រាំពីរ)សំរាប់កម្មករនិយោជិតម្នាក់ៗ។ ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថមនេះនៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២៣។
៣. ចំពោះប្រាក់រង្វាន់ឧបត្ថមការដេរ គឺត្រូវគិតតាមអត្រាបុងដេរកម្មករនិយោជិតម្នាក់ៗដេរបានបុងចំនួនដែលក្រុមហ៊ុនបានកំណត់ ៤៧.៧៤ដុល្លា គឺទទួលបាន៦ដុល្លា និង ដេរបានបុងកំណត់ចំនួន៤៣.៨៣ដុល្លា គឺទទួលបាន១ដុល្លា។
៤. ប្រាក់ថ្លៃធ្វើដំណើរ និងស្នាក់នៅ ក្រុមហ៊ុនផ្តល់ជូនពេញ។
៥. ប្រាក់ថែទាំកូន ក្រុមហ៊ុនផ្តល់ជូនពេញ។
៦. ប្រាក់រង្វាន់ម៉ាស៊ីនឡេគ្រា និងរង្វាន់ក្តាខៀន និងប្រាក់រង្វាន់ឃ្លាំងឡើងនិងទំលាក់ទំនិញ ក្រុមហ៊ុននឹងផ្តល់ជូនដូចខែកក្កដា ឆ្នាំ២០២៣។
៧. ប្រាក់រង្វាន់ទៀងទាត់ ក្រុមហ៊ុននឹងផ្តល់ជូនពេញដោយផ្អែកចំនួនថ្ងៃធ្វើការ១៨ថ្ងៃ។

អង្គប្រជុំបានចប់វេលាម៉ោង ១០និង នាទី ៣០នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមាន ភាពស្និតស្នាត និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃចន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧
ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

**តំណាងសហជីពមានភាពជាតំណាង**
**និងតំណាងកម្មករ**

ហត្ថលេខា និងត្រា
នាយកក្រុមហ៊ុន

QUANTUM APPAREL (CAMBODIA) LIMITED

Lakshman Dayasiri